Australian Government

GLOBAL INITIATIVE AGAINST TRANSNATIONAL ORGANIZED CRIME

ជំនួយកិច្ចសហការនៃកម្មវិធីបណ្តាញមេគង្គ ដើម្បីប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន(MNET-CTC)

កម្មវិធីបណ្តាញមេគង្គ ដើម្បីប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន (Mekong Network to Counter Transnational Crime – MNET-CTC) កំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គារសង្គមស៊ីវិល រួមមានតំណាងអង្គការមិនមែនរដ្ឋាភិបាល អ្នកសារព័ត៌មាន និងអ្នកសិក្សាស្រាវជ្រាវ ដែលពួកគេជាញឹកញាប់ជាអ្នកធ្វើការជួរមុខ និងជាអ្នកឆ្លើយតបដំបូងចំពោះឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង។ ដើម្បីពង្រឹងភាពធន់របស់សហគមន៍ដែលរងផលប៉ះពាល់ពីឧក្រិដ្ឋកម្មទាំងនេះ កម្មវិធីMNET-CTC ស្វាគមន៍អង្គការទាំងនេះឱ្យដាក់សំណើគម្រោងសហការដែលមានគោលបំណងនៅក្នុងការឆ្លើយតប និងទប់ស្កាត់បទល្មើសគ្រឿងញៀន បទល្មើសហិរញ្ញវត្ថុ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។

ជំនួយសម្រាប់គម្រោងសហការនេះ ផ្តល់ឱកាសពិសេសដល់អង្គការសង្គមស៊ីវិលក្នុងការរួមគ្នាប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្ម ក្នុងនាមជាផ្នែកមួយនៃសហគមន៍អនុវត្តការងារ (Community of Practice) របស់កម្មវិធី MNET-CTC។ គម្រោងនេះបង្កើតឡើងមានគោលគំនិតជាការបង្កើនកិច្ចសហការរវាងតួអង្គនានា ដែលនឹងនាំឱ្យមានគំនិតផ្តួចផ្តើមនៅក្នុងសហគមន៍ដែលមានភាពធន់កាន់តែខ្លាំង ហើយឥទ្ធិពលនៃគំនិតផ្តួចផ្តើមទាំងនោះនឹងកាន់តែប្រសើរឡើង នៅពេលដែលដៃគូមានឱកាសរៀនសូត្រពីគ្នាទៅវិញទៅមក អភិវឌ្ឍជំនាញថ្មីៗ និងក្តាប់បទពិសោធន៍របស់ពួកគេនៅទូទាំងតំបន់។

គម្រោងដែលទទួលបានជំនួយសម្រាប់កិច្ចសហការនេះ នឹងត្រូវរៀបចំ និងអនុវត្តដោយអង្គការសង្គមស៊ីវិល ដោយមានការគាំទ្រ និងការត្រួតពិនិត្យពីអង្គការគំនិតផ្តួចផ្តើមសកលប្រឆាំងនឹងឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំងឆ្លងដែន (GI-TOC)។ ការសហការនេះ ដើម្បីជានាគម្រោងនេះឆ្លើយតប និងសម្របខ្លួនទៅតាមតម្រូវការរបស់សហគមន៍មូលដ្ឋាន ព្រមទាំងអាចទាញយកអត្ថប្រយោជន៍ពីបទពិសោធន៍រួម និងការអនុវត្តល្អបំផុតរួមគ្នា និងនៅលើពិភពលោក។

តើជំនួយសម្រាប់គម្រោងសហការរបស់MNET-CTC ផ្តល់អ្វីខ្លះ?

- ថវិកាសម្រាប់អនុវត្តគម្រោង ដើម្បីពង្រឹងភាពធន់នៅកម្រិតសហគមន៍ ក្នុងការប្រឈមនឹងឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង។
- ការគាំទ្រក្នុងការកសាងសមត្ថភាពសម្រាប់អង្គការ និងដៃគូសំខាន់ៗរបស់ពួកគេ។
- ក្លាយជាសមាជិកភាពក្នុងសហគមន៍មូលនិធិភាពធន់(Resilience Fund Community) របស់ GI-TOC និងបណ្តាញការងារទូលំទូលាយរបស់ GI-TOC ព្រមទាំងទទួលបានឱកាសសិក្ខារៀនសូត្រ កិច្ចសហការ និងការទទួលបានជំនួយនាពេលអនាគត តាមភាពសមស្រប។
- ឱកាសចូលរួមក្នុងសិក្ខាសាលាបន្ថែម កិច្ចសន្ទនាស្តីពីការអភិវឌ្ឍ និងកិច្ចសន្ទនាស្តីពីភាពធន់ ក្រោមកម្មវិធី MNET-CTC តាមតម្រូវការចាំបាច់ជាក់ស្តែង។

គោលដៅរបស់យើង

អ្នកពាក់ព័ន្ធសំខាន់ៗមកពីអនុតំបន់មេគង្គអាចកសាងភស្តុតាង សមត្ថភាព
និងទំនាក់ទំនងចាំបាច់ ដើម្បីពួកគេអាចមានឥទ្ធិពល និងផ្តល់ជាមូលដ្ឋានសម្រាប់
រៀបចំគោលនយោបាយ និងការអនុវត្តការងារ
ក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំងឆ្លងដែន។

ព័ត៌មានលម្អិតអំពីសកម្មភាព

យើងកំពុងស្វែងរកគម្រោងសហការដែលប្រកាន់យកវិធីសាស្ត្រផ្អែកលើសហគមន៍
ដើម្បីដោះស្រាយផលប៉ះពាល់ជាក់លាក់នៅមូលដ្ឋាន
ដែលបង្កឡើងដោយឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង។
សកម្មភាពដែលស្នើឡើងត្រូវឆ្លើយតបនឹងប្រភេទឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំងមួយ
ឬច្រើន ក្នុងចំណោមឧក្រិដ្ឋកម្មទាំង៣ប្រភេទខាងក្រោម ព្រមទាំងកត្តាជំរុញ
និងកត្តាអំណោយផលដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មទាំងនេះ៖

- គ្រឿងញៀនខុសច្បាប់
- បទល្មើសហិរញ្ញវត្ថុ
- ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ

សកម្មភាពដែលស្នើឡើងអាចមានទម្រង់ផ្សេងៗគ្នា
ប៉ុន្តែត្រូវផ្តល់លទ្ធផលដែលរួមចំណែកដល់ការសម្រេចគោលដៅរបស់យើង។
សកម្មភាពទាំងនោះត្រូវប្រកាន់យកវិធីសាស្ត្រពង្រឹងភាពធន់របស់សហគមន៍ក្នុងការប្រឈមនឹង
ឧក្រិដ្ឋកម្មរៀបចំជាក្រុម។ នេះមានន័យថា
ត្រូវបង្ហាញឱ្យបានច្បាស់អំពីទំនាក់ទំនងរវាងសកម្មភាពឧក្រិដ្ឋកម្ម
ផលប៉ះពាល់អវិជ្ជមានរបស់វានៅក្នុងសហគមន៍ និងមធ្យោបាយដែលអាចប្រើប្រាស់ដើម្បីទប់ទល់
សម្របខ្លួន និងរំខានដល់ប្រព័ន្ធប្រតិបត្តិការរបស់បណ្តាញឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង។

កម្មវិធី MNET-CTC សូមស្វាគមន៍ការដាក់ពាក្យពីអង្គការនានានៅទូទាំងប្រទេសកម្ពុជា ឡាវ
មីយ៉ាន់ម៉ា[1]ថៃ និងវៀតណាម សម្រាប់គម្រោងប្រកបដោយនវានុវត្តន៍
ដែលតម្រូវឱ្យមានកិច្ចសហការរវាងអង្គការចំនួនពីរ ឬបី។

[1] Myanmar engagement will be reviewed on a case-by-case basis, should operating context allow.

សំណើគម្រោងសហការរវាងអង្គការដែលមានមូលដ្ឋាននៅប្រទេសផ្សេងៗគ្នាក្នុងតំបន់មេគង្គ
នឹងត្រូវផ្តល់អាទិភាព។

អ្នកដាក់ពាក្យគោលដៅសម្រាប់ជំនួយថវិកាសម្រាប់គម្រោងសហការ៖

- អង្គការសហគមន៍មូលដ្ឋាន
- អង្គការមិនស្វែងរកប្រាក់ចំណេញ និងអង្គការមិនមែនរដ្ឋាភិបាល
- អង្គការប្រព័ន្ធផ្សព្វផ្សាយ
- អង្គការស្ត្រី និងយុវជន
- អង្គការផ្អែកលើជំនឿសាសនា
- ពាក្យស្នើសុំពីអង្គការប្រភេទផ្សេងទៀត ក៏អាចត្រូវបានពិចារណាផងដែរ។
  សូមមើលគោលការណ៍ណែនាំស្តីពីឱកាសទទួលបានជំនួយថវិកា។

កិច្ចសហការ

យើងលើកទឹកចិត្តឱ្យអង្គការនានាដាក់ពាក្យស្នើសុំរួមគ្នា
ដើម្បីអនុវត្តសកម្មភាពដែលទទួលបានជំនួយ។ ពាក្យស្នើសុំដោយអង្គការតែមួយ
ដែលមានគុណភាពខ្ពស់
និងស្នើឡើងនូវមធ្យោបាយផ្សេងទៀតសម្រាប់បង្កើតកិច្ចសហការក៏នឹងត្រូវបានពិចារណាផងដែរ
ដោយផ្អែកលើលទ្ធភាពថវិកា។

សម្រាប់ការដាក់ពាក្យរួមគ្នា អង្គការដែលចូលរួមត្រូវជ្រើសរើសអង្គការមួយជាអង្គការដឹកនាំ
ដើម្បីដាក់សំណើគម្រោង ហើយត្រូវកំណត់
និងពិពណ៌នាអំពីតួនាទីរបស់ដៃគូនីមួយៗឱ្យបានច្បាស់លាស់។
អង្គការទាំងអស់ដែលចូលរួមអនុវត្តគម្រោងត្រូវបញ្ជាក់អត្តសញ្ញាណឱ្យបានច្បាស់
ហើយដៃគូនីមួយៗត្រូវដាក់លិខិតគាំទ្រផងដែរ។

តួនាទី និងការទទួលខុសត្រូវរបស់អង្គការដៃគូនីមួយៗត្រូវកំណត់ឱ្យបានច្បាស់លាស់។
អង្គការត្រូវទទួលខុសត្រូវលើការដាក់ពាក្យស្នើសុំ។
អង្គការដៃគូក៏ត្រូវព្រមព្រៀងគ្នាអំពីការបែងចែកការងារ និងរបៀបបែងចែក ថវិកា
ព្រមទាំងផ្ទេរថវិកាទៅឱ្យដៃគូនីមួយៗផងដែរ។

ថវិកាដែលអាចទទួលបាន និងរយៈពេលអនុវត្ត

- ជំនួយភាគច្រើនមានចំនួនចន្លោះពី ៣០,០០០ដុល្លារអូស្ត្រាលី ដល់ ៦៥,០០០ ដុល្លារអូស្ត្រាលី។
- រយៈពេលអនុវត្តគម្រោងចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៧ ដល់ថ្ងៃទី១៥ ខែកុម្ភៈ
  ឆ្នាំ២០២៨។

បេក្ខជនដែលទទួលបានពិន្ទុខ្ពស់ក្នុងកម្រងសំណួរមុនពេលដាក់ពាក្យ
(សូមមើលព័ត៌មានខាងក្រោម) នឹងត្រូវបានអញ្ជើញឱ្យដាក់សំណើថវិកា
ជាផ្នែកមួយនៃពាក្យស្នើសុំពេញលេញ។ បេក្ខជនគួរពិចារណាអំពីរយៈពេល
និងភាពស្មុគស្មាញនៃសកម្មភាពដែលបានស្នើឡើង នៅពេលរៀបចំសំណើថវិកា
និងឯកសារផ្សេងៗសម្រាប់ការដាក់ពាក្យ។

ដំណើរការដាក់ពាក្យ

ដើម្បីដាក់ពាក្យ អ្នកត្រូវ៖

១) បំពេញកម្រងសំណួរមុនពេលដាក់ពាក្យ https://globalinitiative.net/wp-content/uploads/2025/10/Khmer-Pre-Application-Questionnaire-Khmer-new_2026.docx

២) ប្រសិនបើត្រូវបានអញ្ជើញ ត្រូវបំពេញទម្រង់សំណើគម្រោងពេញលេញ និងរៀបចំថវិកាដោយផ្អែកលើសកម្មភាពនីមួយៗ។

អ្នកត្រូវដាក់កម្រងសំណួរមុនពេលដាក់ពាក្យក្នុងអំឡុងពេលកំណត់សម្រាប់ការបើក និងបិទទទួលពាក្យ ដែលបានប្រកាសជាសាធារណៈ។
យើងនឹងមិនទទួលយកពាក្យស្នើសុំដែលដាក់ឃីតជាងកាលកំណត់ឡើយ។

ពាក្យស្នើសុំអាចដាក់ជាភាសាអង់គ្លេស ឬភាសាសំខាន់មួយក្នុងចំណោមភាសានៃតំបន់មេគង្គ (ខ្មែរ ឡាវ ថៃ ឬវៀតណាម)។ ឯកសារសម្រាប់ដាក់ពាក្យជាភាសាទាំងនេះ អាចរកបាននៅ https://globalinitiative.net/announcements/calling-innovative-proposals-to-combat-organized-crime-in-the-mekong/ ។

ប្រសិនបើពាក្យស្នើសុំរបស់អ្នកទទួលបានជោគជ័យ យើងរំពឹងថា
អ្នកនឹងអាចចាប់ផ្តើមអនុវត្តសកម្មភាពគម្រោងដែលទទួលបានជំនួយ នៅក្នុងខែកុម្ភៈ ឆ្នាំ២០២៧។

កាលវិភាគនៃការផ្តល់ជំនួយថវិកា	
រយៈពេលបើកទទួលពាក្យស្នើសុំ៖	ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៦ ដល់ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៦ វេលាម៉ោង ២៣:៥៩ (ម៉ោងនៅអឺរ៉ុបកណ្តាល – CEST)
រយៈពេលនៃការវាយតម្លៃ៖	ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៦ ដល់ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៧
រយៈពេលអនុវត្តគម្រោង៖	ខែកុម្ភៈ ឆ្នាំ២០២៧ ដល់ខែកុម្ភៈ ឆ្នាំ២០២៨

ព័ត៌មានទំនាក់ទំនង និងការដាក់ពាក្យ៖

យើងសូមណែនាំឱ្យអ្នកអានគោលការណ៍ណែនាំពេញលេញស្តីពីឱកាសទទួលបានជំនួយនៅលើគេហទំព័ររបស់យើងតាមរយៈតំណភ្ជាប់៖ https://globalinitiative.net/wp-content/uploads/2026/11/Khmer-Grants-Opportunities-Guidelines.pdf

ប្រសិនបើអ្នកមានសំណួរ សូមទាក់ទងតាមអ៊ីម៉ែល៖

mnet-ctc-resilience@globalinitiative.net

សូមផ្ញើកម្រងសំណួរមុនពេលដាក់ពាក្យរបស់អ្នកទៅកាន់អាសយដ្ឋានអ៊ីម៉ែលខាងលើ ត្រឹមថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៦ វេលាម៉ោង ២៣:៥៩ តាមម៉ោងCEST។

អំពីកម្មវិធី MNET-CTC៖

បណ្តាញមេគង្គ ដើម្បីប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន (Mekong Network to Counter Transnational Crime – MNET-CTC) គឺជាកម្មវិធីរយៈពេលប្រើនឆ្នាំ
ដែលអនុវត្តដោយអង្គការគំនិតផ្តួចផ្តើមសកលប្រឆាំងនឹងឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំងឆ្លងដែន (GI-TOC) ដោយភាពជាដៃគូជាមួយ
រដ្ឋាភិបាលអូស្ត្រាលី។

កម្មវិធី MNET-CTC ទទួលស្គាល់ពីឥទ្ធិពលទិន្នន័យនិងការរិភាគដែលនាំមកនូវការផ្លាស់ប្តូរនៃ
ហើយមានគោលបំណងពង្រឹងមូលដ្ឋានភស្តុតាងស្តីពីនិន្នាការនៃឧក្រិដ្ឋកម្មដែលមានអង្គការចាត់
តាំង ព្រមទាំងលើកកម្ពស់ការយល់ដឹងអំពីផលប៉ះពាល់នៃទីផ្សារខុសច្បាប់នៅក្នុងប្រទេសកម្ពុជា
ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម។

កម្មវិធី MNET-CTC
បង្កើតឱកាសសម្រាប់ការចែករំលែកចំណេះដឹងនេះជាមួយនៃគូពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន
និងថ្នាក់តំបន់ តួអង្គរដ្ឋាភិបាល និងវិស័យឯកជន
ក្នុងគោលបំណងកសាងសហគមន៍អន្តរវត្តការងារក្នុងតំបន់ ដែលធ្វើការរួមគ្នា
ដើម្បីពង្រឹងភាពធន់ក្នុងការប្រឈមនឹងឧក្រិដ្ឋកម្មទាំងនេះ៕